ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល

# ស្តីពី

# ការបង្ការបញ្ហាសុខភាពបណ្តាលមកពីការពុលដោយការបរិភោគត្រីក្រពត

ដោយសារតែករណីស្លាប់បង្កឡើងដោយការបរិភោគត្រីក្រពតនៅតែបន្តកើតមាន នៅបណ្តាខេត្តមួយចំនួន ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណជនទាំងអស់ជ្រាបថា ចាប់ពីឆ្នាំ២០១៧ មកដល់ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៩ មានករណីពុល និងបណ្តាលឲ្យស្លាប់ ដោយសារបរិភោគត្រីក្រពត ចំនួន ០៥នាក់ ក្នុងចំណោមអ្នកឈឺ ចំនួន៤០នាក់ ដែលករណីនេះ បានកើតមាននៅខេត្តក្រចេះចំនួន២លើក ក្នុងឆ្នាំ២០១៧ ខេត្តកោះកុង ១ លើកក្នុងឆ្នាំ២០១៨ ខេត្តសៀមរាប ១លើកក្នុងឆ្នាំ២០១៨ និងខេត្តបន្ទាយមានជ័យ ៣លើក ដែល២លើក កើតក្នុងឆ្នាំ ២០១៧ និង ១លើកទៀត ទើបតែកើតមានឡើងនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៩ នេះ ដែលករណីចុងក្រោយនេះ កើតមានលើគ្រួសារមួយដែលបណ្តាលឲ្យពុលឈឺ៥នាក់ ក្នុងនោះស្លាប់១នាក់។

កន្លងមក ក្រសួងសុខាភិបាលតែងតែធ្វើការណែនាំ និងរំលឹកចំពោះវិធានការការពារករណីពុលចំណីអាហារ ដែលមានទាំងការពុលបណ្តាលមកពីការបរិភោគត្រីក្រពតជាបន្តបន្ទាប់។ នៅក្នុងប្រទេសកម្ពុជា មានត្រីក្រពតចំនួន ១០ ប្រភេទ ក្នុងនោះមាន ៣ ប្រភេទមានជាតិពុល។ តាមការស្រាវជ្រាវបានរកឃើញថា ត្រីក្រពតដែលមានជាតិពុលនោះ រួមមាន៖ Tetraodon cochinchinensis, Monotrete leiurus និង Tetraodon fluviatilis ដែលមានភិនភាគដូចក្នុងរូបភាពភ្ជាប់ជូនខាងក្រោមនេះស្រាប់។ ត្រីក្រពតទាំងនេះ មានជាតិពុលដែលមាន សក្តានុពលខ្ពស់ និងអាចបណ្តាលឲ្យមានជំងឺធ្ងន់ធ្ងរ និងស្លាប់បាន។ នៅពេលយើងបរិភោគត្រីទាំងនេះ ជាតិពុលបានជ្រាបទៅប៉ះពាល់ប្រព័ន្ធសរសៃប្រសាទកណ្តាល និងអាចបណ្តាលឲ្យស្លាប់។

ត្រីក្រពតដែលមានសារធាតុពុលទាំង៣ប្រភេទខាងលើនេះ មានជាតិពុលខ្ពស់បំផុតនៅរដូវពងកូនបន្តពូជ ដែលជាធម្មតាកើតឡើងនៅក្នុងខែកុម្ភៈ មីនា និងចន្លោះខែកក្កដា ទៅខែកញ្ញា។ ចំពោះជាតិពុលនៅក្នុងខ្លួនត្រី ក៏មានកម្រិតខុសគ្នាដែរ គឺពង និងមេជីវិត របស់វា មានជាតិពុលខ្ពស់ជាងគេ បន្ទាប់មក គឺថ្លើម ពោះវៀន ស្បែក និងសាច់។

រោគសញ្ញាចាប់ផ្តើមក្នុងរយៈពេល ២០នាទី ទៅ ២ម៉ោង បន្ទាប់ពីបានបរិភោគត្រីបែបនេះ។ រោគសញ្ញា រួមមាន រមាស់ចាក់ៗ នៅបបូរមាត់ និងមាត់ បន្ទាប់មកមានអាការៈ ឈឺក្បាល វិលមុខ រមាស់ចាក់ៗនៅចុងអវៈយវៈ មានការពិបាកនិយាយ បាត់លំនឹងដងខ្លួន ខ្សោយសាច់ដុំ ខ្វិន ស្ពឹកចុងដៃចុងជើង ក្អួត រាក ល្ហិតល្ហៃ រឹងថ្គាម ឬអាចបណ្តាលឲ្យស្លាប់តែម្តង។ នៅក្នុងករណីដែលពុលខ្លាំង ការស្លាប់អាចបណ្តាលមកពីការថប់ដង្ហើម។ ក្រោយពីពុលភ្លាមៗ ការធ្វើឲ្យក្អួត (ប្រសិនបើអាចធ្វើទៅបាន) អាចជួយបញ្ចេញជាតិពុលពីក្នុងខ្លួនយើងបានមួយចំណែក ហើយអ្នកពុលនោះត្រូវប្រញាប់ប្រញាល់មកស្វែងរកការជួយសង្គ្រោះជាបន្ទាន់នៅមូលដ្ឋានសុខាភិបាលសាធារណៈដែលនៅជិតលោកអ្នកបំផុត ដោយស្ថានភាពអ្នកពុលតម្រូវឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យ តាមដាន ពីគ្រូពេទ្យជាចាំបាច់។ ប្រសិនបើលោកអ្នក មានរោគសញ្ញាដូចរៀបរាប់ខាងលើ កើតមានឡើងបន្ទាប់ពីបានបរិភោគត្រីក្រពត សូមបងប្អូនប្រញាប់ទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលនៅជិតផ្ទះលោកអ្នកជាបន្ទាន់ និងសូមប្រាប់គ្រូពេទ្យពីការដែលអ្នកបានបរិភោគត្រីក្រពត។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) [illegible]

ជាថ្មីម្តងទៀត **ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមធ្វើការក្រើនរំលឹក ណែនាំ និងអំពាវនាវដល់សាធារណជនទាំងអស់ ឲ្យមានការប្រុងប្រយ័ត្ន និងចូលរួមអនុវត្តវិធានការបង្ការការពុលចំណីអាហារ ជាពិសេសការរួមគ្នាអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវអនាម័យចំណីអាហារល្អ គ្រប់ៗគ្នាចាប់តាំងពីអ្នកបរិភោគរហូតដល់អ្នកបម្រើអាហារ ដើរតួនាទីសំខាន់នៅក្នុងការលើកកម្ពស់សុវត្ថិភាពចំណីអាហារចាប់តាំងពីការរៀបចំចំណីអាហាររបៀបទុកដាក់ និងពេលចម្អិនអាហារ។ ដើម្បីជៀសវាងបាននូវបញ្ហាសុខភាព ដែលអាចធ្វើឲ្យបាត់បង់ជីវិតបាន និងដើម្បីជៀសផុតពីការពុលត្រីក្រពតដូចករណីខាងលើ សូមបងប្អូនប្រជាពលរដ្ឋ **សូមកុំបរិភោគត្រីក្រពតដែលមានជាតិពុល** ដោយសារវាមានជាតិពុលនៅក្នុងខ្លួនវាដែលអាចបណ្តាលឲ្យស្លាប់បាន។ ជាតិពុលនៅក្នុងខ្លួនត្រីក្រពតនេះ មិនអាចកំចាត់ចោលបានទេ ទោះបីជាបានចំអិន ឬដាក់ឲ្យកកក៏ដោយ ដូច្នេះសូមបងប្អូនប្រជាពលរដ្ឋកុំបរិភោគត្រីក្រពត។

ក្រសួងសុខាភិបាលសូមលើកទឹកចិត្តឲ្យសាធារណជនទូទៅអនុវត្តតាមដំបូន្មានសាមញ្ញខាងលើ ដើម្បីការពារអ្នកនិងក្រុមគ្រួសារ និងសូមជូនពរអ្នកទាំងអស់គ្នាជួបនូវសុខភាពល្អ ។

ក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណជន អំពីការវិវត្តនៃបញ្ហាសុខភាពតាមគេហទំព័ររបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង www.cdcmoh.gov.kh និងហ្វេសប៊ុកនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល។

សំរាប់ព័ត៌មានបន្ថែម៖ សូមទាក់ទងលេខទូរស័ព្ទទាន់ហេតុការណ៍ដោយឥតគិតថ្លៃ 115 ទោះគ្មានថវិកាក្នុងទូរស័ព្ទរបស់អ្នកក៏អាចទូរស័ព្ទចូលបានដែរ ឬទំនាក់ទំនង៖

ក្រសួងសុខាភិបាល
លោកវេជ្ជបណ្ឌិត លី សូវ៉ាន់ ៖ ០១២ ៨២៥ ៤២៤

ថ្ងៃពុធ ១រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ពស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

## អម្បូរ TETRAODONTIDAE



ត្រីក្រពតបៃតង (Max. 13 cm)
*Auriglobus nefastus*
Greenbottle pufferfish




ត្រីក្រពតភ្នែកក្រហម (Max. 6 cm)
*Carinotetraodon lorteti*
Redeye puffer (ប្រភេទត្រីក្រពតពុល)




ត្រីក្រពតខ្មែរ (Max. 7 cm)
*Monotrete cambodgiensis*
Tetraodontidae




ត្រីក្រពតកូសាំងស៊ីន (Max. 13.5 cm)
*Monotrete cochinchinensis*
(ប្រភេទត្រីក្រពតពុល)



ត្រីក្រពតលឿង (Max. 15 cm)
*Tetraodon abei*



ត្រីក្រពតបន្លា (Max. 12 cm)
*Tetraodon baileyi*



ត្រីក្រពតអុចធំ (Max. 8 cm)
*Tetraodon biocellatus*
Eyespot pufferfish(ប្រភេទត្រីក្រពតពុល)



ត្រីក្រពត (Max. 17 cm)
*Tetraodon fluviatilis*(ប្រភេទត្រីក្រពតពុល)



ត្រីក្រពតអុចបៃតង (Max. 17 cm)
*Tetraodon nigroviridis*
Spotted green pufferfish(ប្រភេទត្រីក្រពតពុល)